D41374
M00208

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ គង់ សុផល អាយុ៣៦ឆ្នាំ ភេទប្រុស
## ភូមិតាត្រាវ ឃុំកំពង់ត្រាច ស្រុករមាសហែក ខេត្តស្វាយរៀង
## សម្ភាសដោយ ៖ ហ៊ាង សុគុណា
## ថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០០៤
## ទំព័រសរុប ៖ ២០ទំព័រ

**កាសែតទី១**

**ខាង អេ**

សុគុណា ៖ ចឹងខ្ញុំជាសិស្សនិស្សិតដែលបានធ្វើការស្ម័គ្រចិត្តនៅមជ្ឈមណ្ឌលឯកសារកម្ពុជាដែលក្នុងគោលបំណងនៃការស្ម័គ្រចិត្តហ្នឹងមានចែកឯកសារជូនបង ។ឯកសារហ្នឹងមានទស្សនាវដ្តីស្វែងរកការពិតហ្នឹងហើយមួយទៀតច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមដែលចុះផ្សាយឡើងដោយរាជរដ្ឋាភិបាលកម្ពុជាហើយមជ្ឈមណ្ឌលឯកសារកម្ពុជាសុំសិទ្ធមកដើម្បីកុបពីមកអោយប្រជាជនបានដឹងហើយចំពោះទស្សនាវដ្តីស្វែងរកការពិតនេះបោះពុម្ពឡើងដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ។ហើយបន្ទាប់មកខ្ញុំសូមស្គាល់ឈ្មោះបងសិនបងឈ្មោះអីដែរបង ។

សុផល ៖ បាទ ខ្ញុំបាទឈ្មោះគង់សុផល ។

សុគុណា ៖ គង់សុផល ។ ហើយឥឡូវអាយុប៉ុន្មានហើយបង?

សុផល ៖ អាយុ ៣៦ឆ្នាំ ។

សុគុណា ៖ ហើយភូមិនេះគេហៅភូមិអីដែរបង?

សុផល ៖ គេហៅឃុំសំបួរនៅភូមិព្រៃកន្ទោត ។

សុគុណា ៖ ភូមិព្រៃកន្ទោត...តែមកនេះ?

សុផល ៖ មកលេងផ្ទះប្អូន ។

សុគុណា ៖ នៅភូមិព្រៃកន្ទោត ឃុំសំបួរ ស្រុករមាស់ហែក ខែត្រស្វាយរៀង ហើយសព្វថ្ងៃបងប្រកបរបបធ្វើអីដែរ?

សុផល ៖ ខ្ញុំប្រកបរបបជុំដែក ។

សុគុណា ៖ ចុះក្រៅពីធ្វើដែកធ្វើអីមានធ្វើអីផ្សេងទៀតទេ?

សុផល ៖ បាទ គ្មានធ្វើអ្វីក្រៅពីដែកទេបង មុខរបរតែមួយ ។

សុគុណ ៖ ដុំតែដែកជានិច្ចកាលតែម្ដង គ្មានធ្វើស្រែធ្វើអីទេ?

សុផល ៖ អត់ទេ ។

សុគុណ ៖ ចឹងបងធ្លាប់បានរៀនសូត្រដល់ថ្នាក់ណា?

សុផល ៖ ខ្ញុំរៀនសូត្របានតិចតួចទេបង ត្រឹមថ្នាក់ទី៦ ។

សុគុណ ៖ ថ្នាក់ទី៦បច្ចុប្បន្ន?

សុផល ៖ ថ្នាក់ទី៦ចាស់ ៗកាលពីមុនគេហៅបឋមសិក្សា ។

សុគុណ ៖ បាទ ៗតែឥឡូវអាចអានអាចអីបានចឹង?

សុផល ៖ បាទអាចអានបាន សរសេរបាន ។

សុគុណ ៖ ហើយជាស្រុកកំនើតបងផ្ទាល់បងនៅណាវិញ?

សុផល ៖ បាទស្រុកកំនើតខ្ញុំផ្ទាល់នៅភូមិពិលឃុំពិលស្រុករមាសហែកខេត្តស្វាយរៀង ។

សុគុណ ៖ ហើយដល់ពេលបច្ចុប្បន្នបងនៅ?

សុផល ៖ ឃុំសំបួរស្រុករមាស់ហែកខេត្តស្វាយរៀង ។

សុគុណ ៖ ហើយបងអាចរៀបរាប់បានទេភូមិប្រវត្តិនៃការកកើតភូមិករណ៏នៅខាងព្រៃគ្នោត កាលពីមុនជីដូនជីតាអីម៉េចៗទេ បងអាចររៀបរាប់បានទេ?

សុផល ៖ ខ្ញុំអាចរៀបរាប់បាន ៗកាលពិតទៅភូមិព្រៃគ្នោតមិនមែនជាខ្សែហ បានន័យថាមិនមែនជាភូមិកំនើររបស់ខ្ញុំទេ ប៉ុន្តែខ្ញុំធ្លាប់ឪពុកមាខ្ញុំជាឪប្អូនរបស់ខ្ញុំគាត់នេះ គាត់នាំខ្ញុំទៅដំដែកដែកនៅទីនោះ ដល់ពេលចឹងខ្ញុំមានប្រពន្ធ ការហើយខ្ញុំអត់មានមុខ ការខ្ញុំក៏ចាប់អាជីពតាមគាត់ បន្តតំនែងពីគាត់មក ខ្ញុំអាចទៅរស់នៅព្រៃគ្នោតហ្នឹង ខ្ញុំអាចប្រកបរបរចិញ្ចឹមជីវិតបានមកដល់សព្វថ្ងៃ ។

សុគុណ ៖ ហើយចុះចំពោះសាសនា ទំនៀមទំលាប់អីនៅគោរពធម្មតា?

សុផល ៖ បាទនៅគោរពធម្មតា ។

សុគុណ ៖ អត់មានខុសពីមុនទេ?

សុផល ៖ អត់ទេ ។

សុគុណ ៖ ហើយដល់ពេលនៅឆ្ងាយចឹង មានវិហាររឺក៏សាវ៉ាវអីសំរាប់គោរពដែរ?

សុផល ៖ អត់មានទេបង...យើងគ្រាន់តែជួបជុំគ្នានៅសាវ៉ាវហ្នឹងដដែលតែសាវ៉ាវនៅស្រុក....... ។

សុគុណ ៖ ចឹងបើថ្ងៃធម្មតាគឺនៅផ្ទះចឹងទៅ ។

សុផល ៖ បាទនៅផ្ទះ ។

សុគុណ : និយាយចឹងតាំងពីតូចមកធំដឹងក្តីប៉ុនហ្នឹងបងដែលឆ្លងកាត់ទេរបបលលន់នុលនិងរបបខ្មែរខ្មែរក្រហមដែររឺទេ?

សុផល : បាទ លន់នល់ខ្ញុំមិនដែលឆ្លងកាត់ទេ ខ្ញុំកើតនៅឆ្នាំ ១៩៦៩ ។ខ្ញុំមិនដឹងថាលន់នល់ឆ្នាំណាទេ? តែបើរបបខ្មែរក្រហមខ្ញុំអាចដឹងក្តី តាំងពីឆ្នាំ៧៥ - ៧៩ខ្ញុំបានឆ្លងកាត់ពេញ ៤ឆ្នាំហ្នឹង ខ្ញុំស្គាល់ទុក្ខវេទនា លំបាកយ៉ាងណាខ្ញុំស្គាល់ ។

សុគុណ : ហើយចុះបងកាលហ្នឹងស្រុកកំនើតនៅភូមិពិលស្រុកពិលទេ?

សុផល : បាទ ។

សុគុណ : ហើយមកដល់សម័យខ្មែរក្រហមគេជម្លៀសទៅ ហើយកាលគេជម្លៀសហ្នឹងគេជម្លៀសទៅណាវិញ?

សុផល : បាទជម្លៀសទៅខែត្របាត់ដំបងទៅស្រុកមោង ។ ៗ

សុគុណ : ហើយគេជម្លៀសទៅហ្នឹង គេធ្វើអី គេជូនយើងទៅតាមណា អីតាមណាវិញទៅ?

សុផល : គេដឹកជូនយើងតាមរថៈគោ គេជូនយើងទៅមានសំភារះអី ។

សុគុណ : ហើយដឹកពីរថៈគោទៅកំពង់ចំលង?

សុផល : ទៅដល់កំពង់ចំលងអ្នកលឿង ។

សុគុណ : ហើយចេញពីអ្នកលឿង ធ្វើដំនើរតាមអីវិញទៅ?

សុផល : ចេញពីអ្នកលឿងទៅ ជិះកប៉ាល់ ឡើងទៅច្បារអំពៅ ។

សុគុណ : ហើយចេញពីច្បារអំពៅទៅណាវិញទៀតទៅ?

សុផល : ឆ្លងពីច្បារអំពៅគេបញ្ជូនឡើង អូតូរៃដល់វ៉ារថៈភ្លើង ។

សុគុណ : ហើយចឹងគេជូនយើងជិះរថៈភ្លើងដល់សុក្រមោងចឹងទៅ?

សុផល : បាទដល់ស្រុកមោង ។

សុគុណ : ហើយ ដល់ពេលដល់កន្លែង ស្រុកមោងចឹងទៅ បងជួបបងប្អូនខ្មែរឥស្លាមយើងប៉ុន្មានគ្រួសារទៅជាមួយរឺមួយក៏អត់ទេ?

សុផល : អត់មានទេ មានតែប្រជាជនខ្មែរ មានតែគ្រួសារខ្ញុំមួយទេ ។

សុគុណ : មានតែខ្មែរ មានតែគ្រួសារបងមួយទៅទេ ហើយការហ្នឹងគ្រួសារបងមានសមាជិកគ្រួសារប៉ុន្មាននាក់ទៅ?

សុផល : កាលហ្នឹងបងប្អូន ខ្ញុំមានប្រាំនាក់ ។

សុគុណ : ប្រាំអ្នកទាំងគ្រួសារ ទាំងឪពុកម្តាយចឹងទៅ ចឹងទៅដាច់តែបងទាំងគ្រួសារ ។

សុផល : បាទ ។

សុគុណ ៖ ហើយដល់ពេលទៅដល់ហ្នឹងចឹងខ្មែរក្រហមមានអោយបងនិងឪពុកម្ដាយនៅជុំគ្នាអត់?

សុផល ៖ អត់បាននៅជុំគ្នាទេបង ។

សុគុណ ៖ ហើយមូលហេតុអីបានជាគេអត់អោយនៅជុំគ្នា?

សុផល ៖ មូលហេតុដូចថា កុមារដាក់នៅដោយឡែក ៗគេមានមន្ទីរកុមារ ។

សុគុណ ៖ ហើយនៅពេលដែលគេអោយយើងនៅកន្លែងកុមារហ្នឹងគេអោយយើងធ្វើអីៗទៀត?

សុផល ៖ បាទ ការងាររមានដូចជាកាប់ កន្ទ្រាំងខែត្រ ជីកអាង

សុគុណ ៖ ជីកធ្វើអីដែរ?

សុផល ៖ បាទ ខ្ញុំមិនដឹងដែរ ប៉ុន្តែជីកអាងធំៗណាស់ ការងាររមានជីកអាង កាប់កន្ទ្រាំងខែត្រ កាប់អូស ។

សុគុណ ៖ ដូចជាកាប់កន្ទ្រាំងខែត្រ កាប់ធ្វើអីវិញទៅបង?

សុផល ៖ កាប់យកធ្វើជីបង ។

សុគុណ ៖ ធ្វើជីហ្នឹងគេយកទៅធ្វើយ៉ាងម៉េចៗខ្លះទៅ?

សុផល ៖ មិនដឹងធ្វើម៉េចទេបង អ្នកកាប់ផ្សេង អ្នកជញ្ជូនមក មានអ្នកផ្សេង ។

សុគុណ ៖ អ៊ូ....ចឹងគេចែកជំនាញផ្សេងៗគ្នា ។

សុផល ៖ បាទ គេចែកជំនាញគ្នា ។

សុគុណ ៖ ហើយចឹងបងឪពុកម្ដាយ នៅកន្លែងផ្សេងទៀតទៅ ហើយគាត់ធ្វើអីទៅ?

សុផល ៖ ឪពុកម្ដាយ ធ្វើការតាមភូមិបងមានដូចធ្វើស្រែ ។ ឪពុកខ្ញុំគាត់មានជំនាញធ្វើត្បាល់កិនស្រូវ គាត់ធ្វើត្បាល់កិនស្រូវ ត្បាល់ខ្មែរ ។

សុគុណ ៖ អាត្បាល់រវៃដៃហ្នឹង?

សុផល ៖ បាទ ហ្នឹងហើយ ។

សុគុណ ៖ ហើយនិយាយចឹងកាលពីសម័យហ្នឹងបងបាត់បង់បងប្អូនបង្កើតរឺសាច់ញាតិអីទៀតទេប៉ុន្មាននាក់ដែរ?

សុផល ៖ បាទ...បាត់បង់ច្រើនបង ឪពុកមួយ ប្អូន២នាក់ ។

សុគុណ ៖ ប្អូនហ្នឹងប្រុសក៏ស្រី?

សុផល ៖ ប្អូនស្រីមួយនិងប្អូនប្រុសមួយ ។

សុគុណ ៖ និយាយចឹងឪពុកបងឈ្មោះអីទៅ?

សុផល ៖ បាទ ឪពុកខ្ញុំឈ្មោះគង់សុស ។

សុគុណ ៖ ហើយមានដឹង មូលហេតុអីបានគេសំលាប់គាត់ចោលទេ?

សុផល ៖ គេមិនសំលាប់ទេបង គេធ្វើមធ្យោបាយតាមការងារ គេអោយធ្វើការខ្លាំង តែអោយហូបតិច ចឹងគាត់ធ្លាក់ខ្លួន ឈឺដល់រាំមរៃរហូតស្លាប់បាត់បង់ជីវិតដោយសារជំងឺតែម្តង គេមិនបានសំលាប់ផ្ទាល់ដៃទេ ។

សុគុណ ៖ ហើយចុះប្អូនរបស់បងវិញស្លាប់ដោយសារអីដែរ?

សុផល ៖ ប្អូនរបស់ខ្ញុំបាទ វាក៏ដូចជាឪពុករបស់ខ្ញុំដែរ វាស្លាប់ដោយសារការអត់ឃ្លាត ពេលមានជំងឺការហូបចុកវាខ្សោយថ្នាំព្យាបាលវាគ្មាន ។

សុគុណ ៖ ហើយប្អូនបងឈ្មោះអីដែរដែលបានស្លាប់ហ្នឹង?

សុផល ៖ ប្អូនខ្ញុំឈ្មោះ គង់ចំរើន ហើយហ្នឹងគង់ស៊ីណាតមួយ ។

សុគុណ ៖ និយាយចឹងដល់ពេលគេជម្លៀសបងទៅដល់ណោះហ្នឹងហើយ ហើយមកដល់ស្រុកភូមិវិញឆ្នាំណាដែរ?

សុផល ៖ បាទ ខ្ញុំត្រលប់មកដល់ភូមិវិញនៅឆ្នាំ ១៩៨០ ។ ខ្ញុំធ្វើដំនើរពីណោះមក ប្រហែលជា ១ឆ្នាំ គឺ១ឆ្នាំតែម្តង ។

សុគុណ ៖ ធ្វើដំនើររហូតតែម្តង?

សុផល ៖ បាទ គឺដើរថ្មើរជើងបង សមាជិកទៅពីនេះទៅ៥នាក់មកវិញសល់តែ៣នាក់ទេ ។

សុគុណ ៖ ហើយមកដល់វិញពេលដែលឃើញស្រុកភូមិដែលធ្លាប់រស់នៅយ៉ាងម៉េចដែរបង?

សុផល ៖ បាទ មកដល់ភូមិដែលធ្លាប់រស់នៅមានអីសល់ក្រៅពីដើមដូងនិងស្រែដែរធ្លាប់រស់នៅទេបាទ ផ្ទះសំបែងគេរើធ្វើជាការដ្ឋាន ធ្វើជាសហករណ៍អីអស់ហើយ ។

សុគុណ ៖ ចឹងយើងមកវិញសង់ផ្ទះ សង់អីសាថ្មី?

សុផល ៖ បាទ សង់ផ្ទះបានបងប្អូនជួយ បងប្អូនជិតខាង ជីដូនមួយអីចឹង ជួយដូចជាអោយឈើអោយផ្ទះ អោយបាននៅ ។

សុគុណ ៖ ហើយពេលមកដល់ចឹងឃើញបងប្អូនសាច់ញាតិប៉ុន្មានគ្រួសារដែរដែលគេមកនៅមុនចឹង?

សុផល ៖ បាទ បងប្អូនខ្ញុំគាត់មិនជម្លៀសទៅឆ្ងាយទេ ដូចថាគាត់ជម្លៀសត្រឹមអ្នកលឿងអីហ្នឹងណ៎ា វគ្គទី៣បងអត់ទាន់បានឆ្លងទន្លេអ្នកលឿងទេ ដល់ពេលទ័ពសម្តេចហ៊ុនសែនយើងទៅរំដោះបែកទីក្រុងភ្នំពេញ បងប្អូនគឺត្រលប់វិញ បងប្អូនវគ្គ៣ហ្នឹងណ៎ាគឺត្រលប់មកផ្ទះវិញបានមុនខ្ញុំ ។

សុគុណ ៖ និយាយចឹង កាលបងជម្លៀសទៅហ្នឹងវគ្គទីប៉ុន្មានរបស់គេដែរ?

សុផល : វគ្គទី២ បាទ ។

សុគុណ : ហើយដល់ពេលហ្នឹង ពេលធ្វើដំនើរត្រលប់មកវិញគឺធ្វើរដើងរហូត ។

សុផល : បាទរយះពេលមួយឆ្នាំបានដល់ ។

សុគុណ : ហើយកាលហ្នឹងមានស្គាល់ផ្លូវស្គាល់អីដែរបង?

សុផល : ឥឡូវស្គាល់បង ហើយចំនាំបានច្រើនកន្លែង ដូចជានៅព្រៃខ្មែរ នៅមុំព្រៃខ្មែរហ្នឹង មានដើមត្នោត និងរូបដីមួយ ។ហើយកាលពេលនោះ ឋកខុត្តម ប៉ែនសុវណ្ណ គាត់ដើរចែកអង្ករអោយ បានមួយគ្រួសារម្នាក់២០គីឡូ ចាំគាត់ច្បាស់ហើយស្គាល់មុខគាត់ច្បាស់ទៀត ស្គាល់ផ្ទាល់តែម្តង ។

សុគុណ : ហើយបងមានធ្លាប់ដែរលឺគេបង្កើតសាលាក្តីកាត់ទោសមេដឹកនាំខ្មែរក្រហមហើយបើបងលឺ លឺតាមរយះអីដែរ?

សុផល : ខ្ញុំបានលឺតាមរយះប្រព័ន្ធឃោសនារបស់វិទ្យុ សារពត៌មាន ។

សុគុណ : សារពត៌មានតាមរយៈអីខ្លះ?

សុផល : តាមរយៈកាសែត តាមរយៈទូរទស្សន៏និងវិទ្យុ ។

សុគុណ : ហើយបងយល់ឃើញយ៉ាងណាដែរនៅពេលដែលគេបង្កើតសាលាក្តីនេះឡើង?

សុផល : ខ្ញុំយល់ឃើញថាខ្មែរក្រហមគួរតែកាត់ទោស ។

សុគុណ : មូលហេតុអីទៅ?

សុផល : មូលហេតុខ្ញុំជាកូនខ្មែរ ខ្ញុំធ្លាប់រងគ្រោះដោយសារស្នាដៃខ្មែរក្រហម ។

សុគុណ : ហើយចុះក្រៅពីស្នាដៃហ្នឹងទៀតមានអ្វីគួរតែយកទៅកាត់ទោសទៀតទេ?

សុផល : ក្រៅពីស្នាដៃប្រឡាក់ឈាមរបស់ខ្មែរក្រហមខ្ញុំក៏មិនអាចដឹងដែរ ព្រោះខ្ញុំក្មេងជិនាន់ខ្ញុំមិនបានសិក្សាប្រវត្តិខ្មែរក្រហមនោះ យ៉ាងម៉េចយ៉ាងម៉ាទេ ប៉ុន្តែខ្ញុំជាកូនខ្មែរដែរធ្លាប់រស់នៅរបបខ្មែរក្រហម ខ្ញុំធ្លាប់ស្គាល់ការឈឺចាប់ ការវេទនានៅក្រោមបាតដៃប្រឡាក់ឈាមរបស់ខ្មែរក្រហម ។

សុគុណ : និយាយចឹងការនៅហ្នឹងបងមានធ្លាប់ឃើញគេយកមនុស្សទៅសម្លាប់ទេ?

សុផល : បាទ ខ្ញុំបានឃើញបាទ ខ្ញុំបានឃើញផ្ទាល់ៗតែម្តង ។ឧទាហរណ៏ខ្ញុំនៅមន្ទីរកុមារ វាថាដាច់ខាតដើម្បីបក្ស ពួកវានិយាយហា៎ សូមបីថាអ្នកស្រុកភូមិជឿថានារីជាប្រធានកុមារចឹងបងណាស់វាធ្វើបាប ពិសេសនារីហ្នឹងធ្វើបាបផ្ទាល់ចំពោះរូបខ្ញុំតែម្តង នារីហ្នឹងខ្ញុំហូបបាយស្រូបទឹក វាថាឋងហូបបាយប៉ុណ្ណឹងមិនឆ្អែតអីបានជាហូបបាយស្រូបទឹក ការពិតខ្ញុំធ្វើអោយវាតឹងក្រពោះបងណា៎ បានស្រូបទឹកចឹងបានវាទេះបាយខ្ទាយពីដៃខ្ញុំបង

ហើយក្រពុបអស់ទៅ ប្រធានពីលើហ្នឹងទៀតចាប់នារីហ្នឹងចងភ្ជាមហើយទឹមនិងរទេះ គោបង ជាន់ពីនាក់ម្នាងតែម្ដង ខ្ញុំឃើញផ្ទាល់ហ្នឹងភ្នែក ។

សុគុណ : ជាន់ពីនាក់ម្នាងជាន់ម៉េចទៅ?

សុផល : ជាន់ដាក់ទឹមលើក ជាន់តែម្ដង ។

សុគុណ : ជាន់សំលាប់តែម្ដង?

សុផល : បាទ គ្រាន់តែជាន់អោយឃើញ កុំអោយយកគំរូតាមនារីហ្នឹង កុមារីហ្នឹងហ៎ា ។

សុគុណ : ហើយជាន់ទៅស្លាប់ទៅ?

សុផល : អត់បានស្លាប់ទេបង គេបញ្ជូនទៅដាក់គុក ដាក់នៅការដ្ឋាន ។

សុគុណ : ហើយមានដឹង ដោយសារអីទៅបានជាគាត់មកទេះបាយបងចោលអីចឹង?

សុផល : ខ្ញុំមិនដឹងថាអារម្មណ៏គេយ៉ាងម៉េចខ្ញុំក៏មិនដែរដឹងដែរបង គេឃើញខ្ញុំហូបបាយស្រូបទឹក ដល់គេរាល់គ្នាអត់ស្រូបទឹក តែចំនែកខ្ញុំគឺថាដើម្បីចំអែតក្រពះអោយតឹងក្រពះខ្ញុំដាក់ទឹកថែម ហើយដាក់ត្រកួនដាក់អីចឹងណ៎ាអោយតឹងក្រពះ ។

សុគុណ : ចឹងមានអីផ្សេងពីហ្នឹងទៀតទេ?

សុផល : ផ្សេងក្រៅពីការឃើញការជាន់កហ្នឹងបងហ៎េ?

សុគុណ : បាទ ។

សុផល : ឃើញ វាក្នុងកុមារ ។ខ្ញុំបាទនិយាយហ្នឹងគឺរឿងខ្ញុំផ្ទាល់តែម្ដង ខ្ញុំនឹកឪពុកម្ដាយពេក ទៅកន្លែងកុមារ ប្រហែលជាម៉ោង២យប់ចេញមកពីមន្ទីរកុមារដើមខ្នោរ មកឃុំស្នួល ចំងាយដីប្រហែលជា២គីឡូដីបង ។

សុគុណ : នៅស្រុកមោងដដែល?

សុផល : បាទ នៅស្រុកមោងហ្នឹង ។ចេញមកខ្ញុំចេញមកជាមួយនិងពួកម៉ាក់ខ្ញុំហ្នឹងឈ្មោះអាទូ ខ្ញុំដើរពីរអ្នកវាមក មកលេងផ្ទះ លេងម៉ែហ៎ា ថាគេដេកលក់អស់ហើយថាមកជួបម៉ែ ។ ដល់មកដល់ពាក់កណ្ដាលផ្លូវជាប់កងឈ្លបរបស់ខ្មែរក្រហម វាភ្ជួងខ្ញុំពីរនាក់ហ្នឹង ជុំវិញតែម្ដង ។

សុគុណ : ភ្ជួងហើយគេធ្វើម៉េចទៀតទៅ?

សុផល : មានធ្វើម៉េច ពេលភ្ជួងហើយវាសួរខ្ញុំ ថាឯងទៅណាមកណាចឹងហ៎ា ប្អូនខ្ញុំវាមានតិរិះវាថា ប្អូនខ្ញុំឈឺ ទៅតាមម៉ែខ្ញុំអោយម៉ែខ្ញុំទៅមើលប្អូនខ្ញុំ តាមពិតគ្មានប្អូនទេ ខ្ញុំតាមហ្នឹង តាមមកលេងម៉ែទេ ប៉ុន្តែយើងភូតវា ការពិតនោមដាក់ជើងខោបាត់ហើយ ហើយក្មេងអាយុ៧-៨-៩ឆ្នាំហ្នឹង ស្មារតីវាមានហ្នឹងនរអី តែគេភ្ជួងហ្នឹងនោមដាក់ជើងខោបាត់ ។

សុគុណ :	ដល់ពេលភូតចិនទៅ ម៉េចទៀតទៅ?

សុផល :	ភូតថាប្អូនខ្ញុំឈឺចិនទៅតាមម៉ែខ្ញុំ វាថាទៅមកវិញភ្លាមហ៎ា បាទខ្ញុំមក ។

សុគុណ :	ចិនក៏មក?

សុផល :	បាទ វាក៏អោយមក អត់មានវៃដុំអីទេ វាគ្រាន់ភ្លុងកាំភ្លើងទេ ។ មកដល់ផ្ទះខ្ញុំឡើងក្ដៅខ្លួន បានពុកខ្ញុំគាត់គ្រូខ្មែរដែរ គាត់បុកថ្នាំបុកអីអោយផឹកទៅ ឡើងញាក់សាច់ ហើយព្រឹកឡើងម៉ោង ៧បានខ្ញុំទៅវិញ ។

សុគុណ :	ហើយមានចាំឈ្មោះអ្នកដែរភ្លុងបងទេ?

សុផល :	អត់មានស្គាល់ទេបង យប់ ប៉ុន្តែជាកងទ័ពរបស់ខ្មែរក្រហមហើយ ។

សុគុណ :	ហើយយល់ថានៅពេលដែលគេបង្កើតសាលាក្ដីចិនហ៎ាតើវាសមស្របហ្នឹងសាសនាឥស្លាមដែររឺទេ?

សុផល :	បាទ វាសមស្របព្រោះសាសនាអ៊ីស្លាមនៅប្រទេសកម្ពុជា វាគ្មានសាសនាអ៊ីស្លាមណាដែលជៀសផុតពីរបបប៉ុលពតទេ ។បើថាឥស្លាមទើបតែមកថ្មី គេថាម៉េចក៏បានដែរ ប៉ុន្តែសំរាប់ខ្ញុំ..............ទូទាំងប្រទេសអោយតែឥស្លាមរងគ្រោះដូចខ្មែរចិន ។

សុគុណ :	ហើយបងគិតថាវា ការកាត់ទោសហ្នឹងវាសមស្របតាមសាសនាទេដែលសាសនាគេចែងមកថាចិនអត់ ។

សុផល :	បាទក្នុងសាសនា ឥស្លាមហ្នឹងខ្ញុំក៏មិនបានរៀនសូត្រជ្រៅជ្រះដែរ ដោយថាចេះគោរពសាសនា ចេះថ្វាយបង្គំ ចេះអីចឹងបានក៏ប៉ុន្តែក្នុងគម្ពីគ្រឹះរបស់សាសនារបស់ហ្នឹងខ្ញុំមិនអាចអានដឹង ។

សុគុណ :	គម្ពីហ្នឹងអត់មានប្រែជាភាសាខ្មែរអោយយើងស្រួលមើលទេ?

សុផល :	អត់មានទេបង មានតែអ្នកចេះដូចថាទូនចិនហ៎ា គេចេះបកប្រែគម្ពីហ្នឹងគេបកអោយយើងស្ដាប់ គេបកប្រែជាភាសាខ្មែររឺភាសាឥស្លាមអីចឹងហ្នឹង យើងអាចស្ដាប់បានហើយ ។

សុគុណ :	ចឹងគេអត់បានប្រែជាភាសាខ្មែរអោយយើងស្ដាប់?

សុផល :	ខ្ញុំអត់ដឹងដែរ ខាងសាសនាឥស្លាម ។

សុគុណ :	ចឹងបងគិតថាពេលដែលគេបង្កើតសាលាក្ដីឡើងតើវាផ្ដល់អត្ថប្រយោជន៏ចំពោះខ្លួនបងហើយហ្នឹងសង្គមខ្មែរហ្នឹង យ៉ាងម៉េចខ្លះដែរទៅបង?

សុផល :	ការកាត់ទោសគ្មានអត្ថប្រយោជន៏ទេ មានតែខាត ។

សុគុណ :	ខាតយ៉ាងម៉េចទៅបង?

សុផល ៖ ខាគបង់ហ្នឹងណា៎ ដូចលុយកាត់ទោសខ្មែរក្រហមមិនតិចលានទេ អាហ្នឹងបរទេសជំនួយអោយមកកាត់ទោសខ្មែរក្រហម បើយើងទុកខ្មែរក្រហម ដូចថាតាម៉ុកសព្វថ្ងៃនៅមន្ទីរឃុំឃាំងបងណា៎ បើសិនទុកអោយគាត់ ស្លាប់អស់ជីវិតគាត់ទៅ ហើយយើងយកលុយមកកសាងប្រទេស ប្រហែលជាជឿនលឿនជាង បាននេះជាទស្សនៈរបស់ខ្ញុំ ។

សុគុណ ៖ ចឹងប្រសិនបើយើងអត់បានកាត់ទោស បងយល់ថាយើងចំនេញតែលុយហ្នឹងទេ ចុះបើសិនជាកាត់ទោស បងគិតថាវាផ្តល់អីខ្លះដល់ខ្លួនបងវិញមួយក៏អ្នកស្លាប់ទៅ?

សុផល ៖ បាទ បើសិនជារដ្ឋាភិបាលយើងអាចកាត់ទោសខ្មែរក្រហមបាន ខ្ញុំអាចមានអត្ថប្រយោជន៏ច្រើនណាស់ អត្ថប្រយោជន៏ទី១ខ្ញុំអាចស្រាយកំហឹង បំបាត់ការឈឺចាប់មិនចឹង ៗខ្លួនខ្ញុំសព្វថ្ងៃនៅសល់តែ២នាក់បងប្អូនទេ ដោយស្នាដៃរបស់ខ្មែរក្រហម ខ្ញុំអាច ធូរកំហឹង ៗសព្វថ្ងៃ ដូចថាតាម៉ុក គាត់មិនមែនជាអ្នកសំលាប់ឪពុកម្តាយខ្ញុំទេ មិនចឹងបងណា៎?

សុគុណ ៖ បាទ ។

សុផល ៖ អ្នកដែលសំលាប់ឪពុកម្តាយ ខ្ញុំជាអ្នកនៅស្រុកភូមិជាមួយគ្នានេះទេ បើសិនជាតាម៉ុកហ្នឹងមានឋកសារថា ឃុំតាគ្រាវ អ៊ូឃុំកំពង់ត្រាច នេះឈ្មោះនេះជាមេសហករណ៏អោយខ្ញុំកាត់ទោសអោយក៏បានដែរ ត្រឹមសំលាប់ដូចគ្នាខ្ញុំអាចសំលាប់បាន ។

សុគុណ ៖ ប៉ុន្តែជាលក្ខខ័ណ្ឌបងអាចមើលក្នុងទស្សនាវដ្តី?

សុផល ៖ បាទៗ ពេលខ្ញុំយកទស្សនាវដ្តីហ្នឹងទៅអានខ្ញុំអាចសិក្សាដឹងហើយ ។

សុគុណ ៖ អាការកាត់ទោសហ្នឹង គេកាត់ទោសតែមេដឹកនាំជាន់ខ្ពស់និងអ្នកដែរទទួលខុសត្រូវជាន់ខ្ពស់កាលពីរបបហ្នឹងទេ ចំពោះអ្នកដែលធ្វើការនៅតាមមូលដ្ឋាន សហករណ៏អីហ្នឹងគេប្រហែលជាមិនបានលើកយកទៅវិនិច្ឆ័យទេ ។ហើយបើសិនជាអ្នក ដែលធ្លាប់ធ្វើបាបមករស់នៅក្នុងភូមិជាមួយហ្នឹង តើបងយល់ថាយ៉ាងម៉េចដែរ?

សុផល ៖ សព្វថ្ងៃ ខ្ញុំមិនដែលមានការចងកំហឹងទេបាទ ព្រោះថាគេបញ្ជាមកពីលើដែរបាន បើគាត់មិនធ្វើ គឺគាត់ស្លាប់ ដូចតែគ្នា បើមេគេបញ្ជាមកពីលើ ។បើអុកគ្រាញចំពីលើមក បើឋងមិនធ្វើ មានតែឋងងាប់ ។

សុគុណ ៖ ហើយចំពោះពាក្យថាយុត្តិធម៏តើវាមានន័យយ៉ាងម៉េចចំពោះបងនិងចំពោះសង្គម?

សុផល ៖ យុត្តិធម៏គឺការពិតបាទ មានន័យណាស់យុត្តិធម៏ ចំពោះខ្ញុំចំពោះសង្គម ខ្ញុំស្វែងរកតែយុត្តិធម៏ទេបាទ ។

សុគុណ ៖ ហើយយុត្តិធម៏ហ្នឹងវាផ្តល់អត្ថប្រយោជន៏អ្វីខ្លះដល់បង?

សុផល : យុត្តិធម៌អាចផ្តល់ផលប្រយោជន៍អោយខ្ញុំ....ខ្ញុំចង់បានការពិត អត្ថប្រយោជន៍របស់ខ្ញុំវាគ្មានទេ តែថាដើម្បីបំពេញយុត្តិធម៌ដែលកាត់ទោសខ្មែរក្រហមចឹងហ៎ា អោយវាត្រឹមត្រូវ ខ្ញុំយល់ព្រមហើយ ។

សុគុណ : បាទ..ចុះបងយល់ថាយ៉ាងម៉េចដែរក្នុងការចងក្រងប្រវត្តិសាស្ត្រសម័យខ្មែរក្រហមអោយក្មេងជំនាន់ក្រោយបានដឹងអីចឹងហ៎ា?

សុផល : គួរតែចងក្រងបាទ ទុកក្នុងប្រវត្តិសាស្ត្រគ្រប់ចំនុចដើម្បីកុំអោយក្មេងជំនាន់ក្រោយរងគ្រោះដោយរបបប៉ុលពតមួយម្តងទៀត ។

សុគុណ : តើវាមានសារៈប្រយោជន៍អីទៀតដែលក្រៅពីកុំអោយមានរបបហ្នឹងទៀត?

សុផល : សំរាប់របបខ្មែរក្រហម អើរឿងសារៈប្រយោជន៍ ខ្ញុំមិនដឹងទេ ខ្ញុំឆ្លើយត្រង់តែម្តងថាខ្ញុំមិនដឹងព្រោះរបបខ្មែរក្រហមគ្មានសារៈប្រយោជន៍អីសំរាប់ខ្លួនយើងទេពេលយើងធ្វើ-ការគេអោយបាយយើងហូប តែយើងមិនធ្វើការពេលយើងឈឺ...?

សុគុណ : អត់អោយបាយតែម្តង?

សុផល : មានបាយដែរប៉ុន្តែបាយតិចៗ វាមានកំលាំងមធ្យម កំលាំងធំ កំលាំងកុមារ ។ កំលាំងកុមារបាយកន្ទះវែកចឹងទៅ កំលាំងមធ្យមបាយមួយវែក កំលាំងមធ្យមអាវ័យចេះមើលគោហ៎ា ដល់ពេញវ័យ១៨-១៩ បាយមួយគូមចឹងទៅណ៎អូនណ៎ ។

សុគុណ : ហើយចាក់ទងនិងរឿងមួយទៀតដែលខ្មែរក្រហមចូលមកកាន់កាប់ស្រុក-ភូមិពូនៅខែ-ឆ្នាំណាដែរ?

សុផល : ខ្ញុំមិនអាចខែទេ តែខ្ញុំអាចចាំឆ្នាំ១៩៧៥ ។

សុគុណ : ហើយនៅពេលដែលវាកាន់កាប់ហ្នឹងវាធ្វើតាមរបៀបណាខ្លះទៅ?

សុផល : ការវាធ្វើមុនដំបូងវាធ្វើក្រុមសាមគ្គីប្រវាស់ដៃ ។

សុគុណ : ប្រវាស់ដៃហ្នឹងម៉េចទៅ?

សុផល : ប្រវាស់ដៃហ្នឹងវាធ្វើស្រែ គឺថាជួយគ្នាបងប្អូន ដូចថាស្ទូងផ្ទះស្រែបងប្អូនចឹងណាក្នុងមួយឃុំទៅជួយផ្ទះបងមួយ ជួយមួយឃុំអោយរួចហើយមួយថ្ងៃចឹងទៅស្អែកមកដល់ផ្ទះខ្ញុំ អាហ្នឹងគេក្រុមសាមគ្គីប្រវាស់ដៃ ។

សុគុណ : កាលហ្នឹងធ្វើនៅភូមិពិលនេះទេ ។

សុផល : បាទភូមិអំពិល ។

សុគុណ : កាលហ្នឹងនៅធ្វើចូលរួមជាមួយប្រជាជនទាំងអស់គ្នា ចុះនៅពេលដែលគេធ្វើជាសហករណ៏ក្រុមសាមគ្គីអីចឹង តើប្រជាជនមានការតវ៉ាអីទេ?

សុផល : ប្រជាជនមានសិទ្ធិអីតវ៉ាជាមួយគេអ្នកអំណាចធំ យើងមិនតវ៉ាទេ គេបញ្ជាអី យើងធ្វើហ្នឹង យើងតវ៉ា កខ្វី កដូចកហោនេស៊ីឥឡូវហ្នឹង ។

សុគុណ : ហើយកាលពេលដែលវាធ្វើក្រុមសហករណ៍ដំបូងចឹង ប្រជាជនយល់ស្របថាវាធ្វើល្អ ធ្វើអីទេកាលហ្នឹង?

សុផល : ប្រជាជនយល់ថាកាលហ្នឹងល្អ បង្កើតក្រុមសាមគ្គីប្រវាស់ហ្នឹងវាល្អណាស់ ។

សុគុណ : ល្អយ៉ាងម៉េចទៅ?

សុផល : ល្អនេះព្រោះថាយើងធ្វើតែមួយថ្ងៃហើយ ។

សុគុណ : វាលឿន ។

សុផល : បាទវាលឿន ។បើដីថាមានតែ១ហិចតាចឹង ១ភូមិយើងមកជួយទាំងអស់តែមួយថ្ងៃហើយអស់បាត់ហ៎ា ហើយស្អែកទៅមួយស្រែមួយទៀត ។

សុគុណ : និយាយចឹងកាលខ្មែរក្រហមមកត្រួតត្រានៅភូមិបងដំបូងតើមានប្រជាជនប៉ុន្មានគ្រួសារដែរ?

សុផល : ខ្ញុំមិនអាចចាំបានទេ កាលនោះប្រសិនជាអោយខ្ញុំរាប់ឈ្មោះវារាប់ព្រោះកាលនោះច្រើនហ៎ា ប្រហែលជា៧០គ្រួសារឡើង ។

សុគុណ : ហើយភាគច្រើនជាបងប្អូនខ្មែរឥស្លាមរឺក៏ជាខ្មែរ?

សុផល : ជាខ្មែរ ឥស្លាមតែគ្រួសារខ្ញុំទេ ។

សុគុណ : ហើយដល់ និយាយចំនៅពេលដែលបែករបបខ្មែរក្រហម បងត្រលប់មកស្រុកកំនើតវិញរឺក៏យ៉ាងណា?

សុផល : បាទៗ

សុគុណ : ហើយកាលបងនៅទីនេះ កាលវាធ្វើសហករណ៍ដំបូងហ្នឹង វាមានអោយបងប្អូនខ្មែរឥស្លាមធ្វើជាអ្នកដឹកនាំដឹកអីទេ?

សុផល : ភូមិខ្ញុំ អត់មានឥស្លាមផង មានតែខ្មែរ គ្មានទេឥស្លាមនៅភូមិអំពិលនេះមានតែគ្រួសារខ្ញុំមួយជាប់សាច់ឈាម ។

សុគុណ : ហើយដល់ពេលវាជម្លៀសទៅដល់បាត់ដំបង ក៏អត់?

សុផល : គ្មានបានដឹកនាំអីទេ ។

សុគុណ : គឺស្ថិតនៅក្រោមការត្រួតត្រារបស់វាទាំងអស់?

សុផល : ត្រួតត្រារបស់វាទាំងអស់ អ៊ីស្លាមគឺត្រូវហូបសាច់ជ្រូក អ៊ីស្លាមណាក៏ដោយអោយតែនៅស្រុកខ្មែរ អ្នកណាក៏ដោយអោយតែកើតនៅឆ្នាំ៧៥ ដឹងដែរបានទទួល

ទានសាច់ជ្រូកហើយ ។

សុគុណ : ដល់តែទទួលទានចឹង ដល់សាសនាយ៉ាងម៉េចដែរបង?

សុផល : អត់សូវដឹងដែរ បើយើងស្លាប់ដោយសារសាសនាជីវិតយើងវាថោកពេក ចឹងក៏យើងសុខចិត្តហូបទៅ សុខចិត្តខុសហ្នឹងសាសនាដើម្បីជីវិតរស់ ។

សុគុណ : បាទយើងបទបែនតាមកាលៈទេសៈ ។

សុផល : បាទបទបែនតាមកាលៈទេសៈទៅ ។

សុគុណ : ហើយនិយាយចឹង កាលពេលដំបូងខ្មែរក្រហមវារៀបចំប្រជាជននៅក្នុងភូមិបងហ្នឹងយ៉ាងម៉េច វារៀបចំជាសហករណ៍តែម្តង រឺក៏មានបង្កើតជាសេវាអីផ្សេងៗដូចជាសុខភាព ការសិក្សាអីៗអត់ទេ?

សុផល : ការសិក្សាមាន មន្ទីរពេទ្យមានប៉ុន្តែវាធ្វើខ្លួនឯង ។

សុគុណ : ថ្នាំវាធ្វើពីអីទៅ?

សុផល : ធ្វើពីរឹសឈើ មានកន្លែងរោងចក្រវាធ្វើដោយផ្ទាល់តែម្តង ហើយគេមានពុម្ពគេមួយគេវៃ សុទ្ធតែអក្សរទាំងហ្នឹង តែអត់មានទិញមកពីបរទេសណាទេ គឺផលិតនៅប្រទេសខ្មែរតែម្តង ។

សុគុណ : ហើយគ្រូខ្មែរគ្រូអីគាត់អ្នកធ្វើ?

សុផល : បាទ គាត់អ្នកផ្សំ ។

សុគុណ : ហើយវៃពុម្ពខ្មែរចឹងទៅ ។

សុផល : ហើយម្សៅដំលូងយើងអីហ្នឹង យកមកលាយអោយខាប់ទៅ ហើយមានពុម្ពគេវៃម្តងរាប់រយគ្រាប់ចឹងទៅ ចែក ។

សុគុណ : វាចេះធ្វើថ្នាំខ្លួនឯង.....ថ្នាំដែរវាធ្វើមកមានប្រសិទ្ធភាពទេ ។

សុផល : មានប្រសិទ្ធភាពដែរបង ចុះផ្សំពីរឹសឈើ ឈឺពោះអីដាក់បាត់ប៉ុន្តែវត្ថុធាតុដើមតែមួយមុខគឺសំបកក្រឡាញ់យើង ។ សំបកក្រឡាញ់យកមកកិនលាយជាមួយម្សៅកាលណឹង បើយើងមិនបានទៅពេទ្យ យកសំបកក្រឡាញ់មកហូបក៏អាចបាត់ដែរ ។

សុគុណ : ហើយក្រោយមកគេមានការផ្លាស់ប្តូរអាការគ្រប់គ្រងធ្វើបែបហ្នឹងដែររឺទេ?

សុផល : ដល់ពេលក្រោយពីប្រវាស់ដៃមកគឺផ្លាស់ប្តូរចូលជាសហករណ៍គឺទ្រព្យសម្បត្តិ ក្របីគោ មាស គឺចូលជាសហករណ៍ទាំងអស់ ។

សុគុណ : ហើយដល់ពេលចឹងទៅប្រជាជននៅមានអារម្មណ៍ល្អទៀតរឺ ក៏យ៉ាងម៉េចទៅ?

សុផល : ប្រជាជនដែរមានអារម្មណ៍ល្អបើគេយក ទ្រព្យសម្បត្តិអស់ហើយ តែធ្វើម៉េច

យើងរើបំរាស់ម៉េចរួច ។

សុគុណ : យើងចូលសងរបស់គេហើយ ។

សុផល : ហ្នឹងហើយចូលសងរបស់គេហើយ....សូមបីតែគេអោយហិតក្តិតគេក៏ហិតដែរ ។

សុគុណ : ហើយបងដឹងដែរនៅពេលណាដែលគេអោយចូលជាសហករណ៏ អីចឹង?

សុផល : បាទចូលជាសហករណ៏ឆ្នាំ ៧៦-៧៧ គឺពេញនិយមតែម្តង ។

សុគុណ : ហើយមូលហេតុបានជាវាធ្វើជាសហករណ៏បងមានដឹងដែរទេ?

សុផល : មូលហេតុដែលវាចូលជាសហករណ៏ខ្ញុំអត់ដឹងទេ វាបាយរួម ការងារក៏រួមដែរ ។
អ្នកណា កំលាំងពេញស្ទូងស្រែ ដូចឳពុកខ្ញុំកាលណឹងអាយុ ៥០.............

## ប្តូរកាសែតរូមកខាងបី

សុគុណ : អ្នកផ្សេងៗទៀតថាមានកំលាំងផ្សេងៗទៀត?

សុផល : ហ្នឹងហើយកំលាំងផ្សេងៗធ្វើការធ្ងន់ៗទៅដូចជាក្រៅពីស្ទូងស្រែទៅកាប់ឈើចឹងទៅ
ទៅលើស្រូវអីទៅ ដាក់គរជាជង្រុកចឹងទៅណ៎ា ។

សុគុណ : ហើយអ្នកដែរកាប់ឈើលើសែងចឹងទៅ គេហៅកំលាំងអីទៅ?

សុផល : បាទ..គេហៅកំលាំងពេញ ។

សុគុណ : ហើយគេចែកកំលាំងហ្នឹងតាមលំដាប់អីខ្លះទៅបង អាចរៀបរាប់ពីដើមសាថ្មីបាន
ទេបង?

សុផល : កំលាំងពេញគេចែកលំដាប់កងចល័ត គេចែកជាក្រុមៗចឹងទៅកងចល័តចឹងទៅ ខ្លះនេះ
ទៅធ្វើជាទាហ៊ានយោធា នៅសេសសល់ចឹងទៅធ្វើជាកងចល័ត ដូចថាគេត្រូវការ
កងសរីការហ៎ា កងសរីការដូចថាអ្នកដឹកនាំរបួស អ្នកសែងអ្នករបួសដាក់តាម
ទីស្នាក់ការតាមឃុំ-ភូមិចឹងទៅ មានរបួសសែងចេញពីវៀតណាមមកចឹងទៅកំពុង
សង្រ្គាមហ៎ា អ្នករបួសចឹងសែងតៗគ្នាមកពីពិលចឹងមកកំពង់ត្រាចចឹង គេសែង
ដាក់កន្លែងហ្នឹង ហើយអ្នកកំពង់ត្រាចសែងដាក់មន្ទីរពេទ្យធំដើម្បីដាក់មកសង្រ្គោះ ។

សុគុណ : និយាយចឹងកាលគេជម្លៀសបងទៅនៅបាត់ដំបង ស្រុកមោងអីនៅឆ្នាំណាវិញទៅ?

សុផល : ឆ្នាំ ១៩៧៨ ។

សុគុណ : ៧៨..ហើយនិយាយចឹងបងមានធ្លាប់លឺថាមានការបោះបោលបងប្អូនយើងជាជនជាតិ
អ៊ីស្លាមអីដែរអត់?

សុផល : មានបងគឺនៅខែត្រកំពង់ចាម ព្រោះថាធ្វើបាបប្រជាជនវាខ្លាំងពេក ប្រជាជនមាន
បោះបោលឡើង ប្រជាជនតស៊ូឡើងដោយស្នា ដាវ កាំបិតហ្នឹងហ៎ា ក៏មិនអាចរើ

បំរាស់រួចដែរ អ្នកតស៊ូទាំងនោះគឺស្លាប់អស់ ។

សុគុណ : បងមានដឹងថាអ្នកជាអ្នកបោះបោលនោះមានឈ្មោះអីៗដែរ?

សុផល : ខ្ញុំមិនអាចដឹងបានទេ មិនបានឃើញផ្ទាល់និងភ្នែកទេ តែចាស់ៗគាត់និយាយ ។

សុគុណ : ហើយនៅពេលណាដែរដែលមានការបោះបោលចឹង?

សុផល : ពេលបោះបោលគឺឆ្នាំប្រហែលជា ៧៨ហ្នឹងតែម្តង វាជិះជាន់ខ្លាំងណាស់បង ៧៨-៧៩ហ្នឹង ៗវាជិះជាន់ខ្លាំង..... ដល់ពេលប្រជាជនអ៊ីស្លាមឈឺចាប់ពេក ក៏មានការផ្ទុះកំហឹងឡើង តស៊ូក៏ប៉ុន្តែមិនអាចសំរេចទេ បាទដោយកំលាំងយើងខ្សោយមួយភូមិជាមួយមួយប្រទេសម៉េចឈ្នះគេ រួចហើយក៏បាត់បង់ជីវិតទៅ ។

សុគុណ : ហើយបងដឹងទេក្រោយពីមានការរើបំរាស់ចឹងទៅ គេមានបានធ្វើអោយប៉ះពាល់អីខ្លះដល់ប្រជាជនអ៊ីស្លាមយើងនៅខាងក្រោយៗនេះ?

សុផល : អត់ប៉ះពាល់ទេបង ប៉ះពាល់តែអ្នករើបំរាស់ទេ ពួកអ៊ីស្លាមនៅខែត្រនានាគេគ្រាន់គៀបសង្កត់យើងកុំរើបំរាស់ ដូចខាងហ្នឹងងាប់ដូចគ្នាហ៎ា ។

សុគុណ : គេគៀបសង្កត់យើងយ៉ាងម៉េចទៅ?

សុផល : គេនិយាយគំរាមចឹងថាបងតែហ៊ានបោះបោលបងងាប់ដូចពួកហ្នឹងចឹង ។

សុគុណ : គេប្រាប់ចឹងតែម្តង ពីណាគេជាអ្នកប្រាប់ដែរ?

សុផល : ប្រធានសហករណ៍អីចឹងទៅ អ្នកមេៗ ។

សុគុណ : មេៗហ្នឹងឈ្មោះអីដែរដែលបានប្រាប់?

សុផល : មេៗដែរបានប្រាប់ហ្នឹងងាប់អស់ហើយ ឈ្មោះអ៊ី ឈ្មោះអ៊ីហ្នឹង តាអ៊ីនៅពិលអីហ្នឹង ។ មិនដែលស្គាល់ឈ្មោះទេ ដឹងត្រកូលគាត់អីទេ គាត់ស្លាប់អស់ហើយ ។

សុគុណ : កាលជម្លៀសទៅបាត់ដំបងទៅកន្លែងផ្សេងហ្នឹងគេជម្លៀសទៅទាំងភូមិៗរឺក៏យ៉ាងម៉េច?

សុផល : គេមិនជម្លៀសទាំងភូមិទេបង គេចុចឈ្មោះ គេមើលប្រវត្តិ អ្នកដែលមានប្រវត្តិមិនល្អ គឺគេជម្លៀសទៅ គេយកទៅសម្លាប់ទៅ ។

សុគុណ : អ៎ូ...ភាគច្រើនពេលគេជម្លៀសហ្នឹងគេយកទៅសម្លាប់ទេ?

សុផល : គេបញ្ជូនទៅសំលាប់ទេ អ្នកដែរជាប់និន្នាការពីមុន៧៥ ដូចជាឪពុកខ្ញុំជាទាហ៊ានបារាំងអីចឹងហ៎ា គេថាឪពុកខ្ញុំឈ្មោះមិនល្អគេបញ្ជូនទៅមាន ។

សុគុណ : គេមើលដឹងតែម្តង?

សុផល : ចុះប្រវត្តិ ជីវប្រវត្តិ គេស្រាវចឹងទៅ អ្នកប្រវត្តិមិនល្អ ខ្លះជាប់ខ្សែវៀតណាមចឹងទៅ

គេបញ្ជូនទៅហើយ គេបញ្ជូនទៅចឹងរបាយការណ៍ទៅដល់ណុំ ។

សុគុណ : និយាយចឹងខ្មែរក្រហមហ្នឹងមានបានប្រព្រឹត្តិលើជនជាតិឥស្លាមហ្នឹងយ៉ាងម៉េចខ្លះ ទាក់ទងនិងរឿងប្រពៃណី ទំនៀមទំលាប់និងការប្រើភាសាអី?

សុផល : ភាសាសំរាប់ជួបមេធំៗចឹងយើងមិនអាចនិយាយបានទេ ។ ប្រពៃណីទំនៀមទំលាប់ ទីមួយហូបសាច់ជ្រូកចឹងបងណាស់ អ្នកឋឹងមិនហូបអ្នកឋឹងត្រូវស្លាប់ កន្លែងតឹងតែង បើកន្លែងធូរៗក៏គេអាចសំរួលដែរបងណុំ ។ ជិនាន់ប៉ុលពតក៏មានខ្មែរឥស្លាមនានាក៏មាន ជាប្រធានសហករណ៏អីចឹងដែរក៏គេអាច តាមខ្ញុំស៊ើបដឹង ក៏គេអាចបន្ធូរបន្ថយ បើថាយើងមិនហូប ក៏មិនហូបទៅ តែដោយភាពអត់ឃ្លាន អ្នកខ្លះក៏ហូបដែរ សូម្បីតែ ឪពុកក្មេកខ្ញុំគាត់អ្នកស្លូតត្រង់បំផុតហើយ គាត់ក៏ធ្លាប់ហូបសាច់ជ្រូកដែរ ។

សុគុណ : ម៉េចបានគាត់ហូបបង? គេបង្ខំមួយក៏គាត់ហេវខ្លាំងពេក?

សុផល : ទីមួយគឺខ្លាចគេតែម្តង ត្រឹមតែហេវគាត់សុខចិត្តស្លាប់ប៉ុន្តែក្រោមអំណាចរបស់គេ គេអោយយើងហូប យើងមិនស្មោះត្រង់និងបក្សយើងស្លាប់ ។

សុគុណ : ចឹងតើបងធ្លាប់ជួបប្រទះខ្លួនឋឹងរឺក៏ឃើញខ្មែរក្រហមសំលាប់ចំពោះអ្នកដែលមិនព្រម លះបង់សាសនា ដែលគាត់មិនព្រមលះបង់សាសនា?

សុផល : ខ្ញុំមិនបានឃើញទេបង ។

សុគុណ : ហើយក្រៅពីមូលហេតុសាសនានិងប្រពៃនីតើមានហេតុផលអីផ្សេងខ្មែរក្រហមធ្វើបាប ប្រជាជនមូស្លីមហ្នឹង?

សុផល : វាមានការមើលងាយ ការជៀលខ្ទិះ ។

សុគុណ : ជៀលខ្ទិះយ៉ាងម៉េចទៅ?

សុផល : ជៀលខ្ទិះអានេះមិនមែនជាជនជាតិខ្មែរ គេជេរថាអានេះអាចាមអីចឹង គេជេរហើយ សូម្បីថាសំរាប់មេធំៗរឺកូនចៅធំៗចឹង កូនចៅបន្ទាប់មក ដូចថាគេមានបុណ្យសក្តិធំៗ ចឹង គេអាចជេរយើងថាអាចាមអីចឹង ។

សុគុណ : ហើយនៅពេលដែលគេជេរអីចឹងទៅចំពោះបងអីមានអារម្មណ៏យ៉ាងម៉េចទៅ?

សុផល : អារម្មណ៏គេជេរទាំងបងឋឹង ទាំងខ្ញុំយើងខឹងហើយ តែយើងមិនអាចធ្វើអីគេកើត ។

សុគុណ : និយាយចឹងហេតុការណ៏ដែរបងធ្លាប់ឆ្លងកាត់តើហេតុការណ៏ណាមួយដែរបងមិនអាច បំផ្លាញមិនបាន?

សុផល : ហេតុការណ៏ដែលមិនអាចបំភ្លេចបានគឺថាទារុណកម្មដ៏ចុកឈាមចឹងតែម្តង ទារុណកម្មដ៏ ឃោរឃៅបំផុតតែម្តង នៅលើលោកហ្នឹងជីវិតរបស់ខ្ញុំមិនដែលជួបប្រទះ ។

សុគុណ ៖ ទារុណកម្មយ៉ាងម៉េចទៅបង?

សុផល ៖ គេធ្វើទារុណកម្មទីមួយគឺគេមិនអោយយើងហូបឆ្អែត គេប្រើធ្វើការងារជាទំងន់ ទាំងកុមារ វ័យជំទង់ និងកំលាំងពេញនិងវ័យជរាអ្នកណាក៏ស្គមស្គាំងរូបកាយដែរ ។

សុគុណ ៖ ចឹងនេះជាទារុណកម្មសាហាវណាស់ ។និយាយចឹងគ្រួសារបងមានកូនចៅប៉ុន្មាននាក់ដែរ?

សុផល ៖ បាទខ្ញុំមានកូន៣ហើយ ។

សុគុណ ៖ ដូចថាមានធ្លាប់ប្រាប់រឿងរ៉ាវហ្នឹងអីទៅកូនទេ?

សុផល ៖ ប្រាប់បង...ប្រាប់ កូនខ្ញុំធ្លាប់សួរថា យាយទៅណា? ខ្ញុំថាយាយអាពតស៊ីអស់ហើយ ។

សុគុណ ៖ ហេតុអីបានជាយើងប្រាប់ចឹង?

សុផល ៖ យើងប្រាប់ត្រង់ចឹងពីព្រោះវាសួររកយាយវា វាកើតមកអត់មានយាយផង សូមបីតែពុកវាហ្នឹងស្គាល់មុខឪពុកម្ដាយតែអាយុ១០ឆ្នាំទេស្គាល់មុខ ម្ដាយស្លាប់ចោលអស់ហើយ តស៊ូត្រដររស់រហូតមកដល់សព្វថ្ងៃ ។

សុគុណ ៖ បងនៅពេលណាដែរកូនសួរហ្នឹង?

សុផល ៖ ពេលកូនសួរហ្នឹង វាសួរប៉ាគេមានយាយ ចុះយាយខ្ញុំទៅណា? យាយកូនតាកូនឋិងប៉ុលពត ស៊ីអស់ហើយ ។

សុគុណ ៖ ហើយតើក្មេងវាគិតយ៉ាងម៉េចដែរ?

សុផល ៖ ខ្ញុំមិនដឹងដែរ....វាសួរថាតើប៉ុលពតមុខដូចម៉េចប៉ា ខ្ញុំថាប៉ុលពតមុខដូចមនុស្សមុខដូចប៉ាចឹង ប៉ុលពតមុខដូចគ្នាកូន ។

សុគុណ ៖ ហើយនិយាយចឹងបងចង់បំភ្លេចរបបហ្នឹងពីក្នុងចិត្តចោលទេ ?

សុផល ៖ សំរាប់រូបខ្ញុំគួរតែបំភ្លេចប៉ុន្តែក្នុងប្រវត្តិសាស្ត្រត្រូវតែចារជាដាច់ខាតតែម្ដង ដើម្បីកុំអោយអ្នកដឹកនាំជំនាន់ក្រោយ វាភ្លៀវផ្លូវចូលក្នុងរបបហ្នឹងម្ដងទៀត កុំអោយកូនខ្មែររងគ្រោះម្ដងទៀត ។

សុគុណ ៖ ហើយមូលហេតុអីដែរបងចងបំភ្លេចចោលខ្លួនឯងហ្នឹង?

សុផល ៖ បាទ មូលហេតុដែលខ្ញុំចង់បំភ្លេចចោលព្រោះសព្វថ្ងៃខ្ញុំរស់ដោយគ្មានអ្នកណាគេសង្កត់ទេ ។អោយតែយើងរក បានប្រជាធិបតេយ្យសេរីចឹងបងណា៎ ។បើសិនជាខ្ញុំមានលុយទិញកប៉ាល់ហោះ ក៏ខ្ញុំអាចទិញជិះបានដែរ វាសេរីបំផុតហើយ ខ្ញុំបានប៉ុណ្ណឹង ខ្ញុំអរគុណហើយ ប៉ុន្តែខ្ញុំគ្រាន់តែចង់ថា កុំអោយរបបហ្នឹងវិលវិញ

យើងចារទុកជាប្រវត្តិសាស្ត្រ ដើម្បីក្មេងជំនាន់ក្រោយកុំអោយថាអ្នកដឹកនាំដូចជាកូនខ្ញុំ កូនប្រជារាស្ត្រទូទាំងប្រទេស ឡើងកាន់ដំនែងដឹកនាំចូលរបបហ្នឹងទៀត កូនខ្មែរយើងវារងគ្រោះ ។

សុគុណ : ចឹងបងមានអីចង់បន្ថែមក្រៅពីខ្ញុំសួរទេ?

សុផល : ខ្ញុំចង់និយាយថា រួចចេញពីកណ្ដាប់ដៃខ្មាមក អាបិសាចដ៏សាហាវ ឃោឃៅខ្ញុំមានតែថ្លែងអំនអរគុណចំពោះអ្នកដែលសង្គ្រោះខ្ញុំ ដូចជាសម្ដេចហ៊ុនសែនហ្នឹងហា៎ គាត់ជាទេវតាមួយទៅហើយណា៎គេដាក់នៅមាត់រណ្ដៅហើយគាត់មកឆក់យើងផុតពីការស្លាប់បាន សូមថ្លែងអរគុណតែប៉ុណ្ណឹងទេ ហើយគ្មានអីជួយគាត់ទេ មានតែថ្លែងអំនរអរគុណ ហើយសូមអោយមេដឹកនាំសម័យកុំអោយចូលដូចមេដឹកនាំសម័យ៧៥ទៀត ចឹងបានថាប៉ុណ្ណឹងរាល់ថ្ងៃ ត្រឹមហ្នឹងចុះ កុំអោយលើស តែលើសរឹកចំរើនជាងហ្នឹងក៏វាលំបាកដែរ តែប៉ុណ្ណឹងក៏បានដែរ យើងរកស៊ីដោយសុទ្ធចិត្ត មិនលួចឆក់ប្លន់គេ រកស៊ីដោយកំលាំងញើសឈាម មិនដែលពីណាមកធ្វើបាបយើងទេ អរគុណហើយបងប៉ុណ្ណឹង ។

សុគុណ : ហើយខ្ញុំសូមសួរទាក់ទងហ្នឹងសាសនាតិចដែរបង ហេតុអ្វីបានជាមស្ជិតហ្នឹងចំបាច់ចំពោះសាសនា?

សុផល : មស្ជិតហ្នឹងគឺជាកន្លែងសំរាប់បូជាសាសនា មស្ជិតហ្នឹងគឺជាបន្ទុលសំរាប់យើងគោរព ។

សុគុណ : ហើយនៅក្នុងគម្ពីសំរាប់សាសនាអ៊ីស្លាមហ្នឹងគេមានចែងយ៉ាងម៉េចដែរចំពោះមស្ជិតហ្នឹង?

សុផល : សាសនាណាក៏ដូចសាសនាណាដែរបងគម្ពីគឺចែងមនុស្សអោយល្អ មែនថាគម្ពីឥស្លាមអីចែងអោយសំលាប់ឪពុកម្ដាយបងអីអត់ទេ គឺដឹកនាំតែយើងធ្វើបាបគឺទទួលផលបាប យើងធ្វើបុណ្យគឺបានបុណ្យ យើងលក់ដូរគឺបានចំនេញ

សុគុណ : ហើយនិយាយចឹងនៅភូមិដែលបងរស់នៅហ្នឹងមានទួនមានអីទេ?

សុផល : អត់មានទេបង ។

សុគុណ : ដាច់តែបងឆ្ងាយហើយចឹងនៅភូមិបងដែលនៅហ្នឹងមានតែមួយគ្រួសារទេ?

សុផល : បាទតែគ្រួសារខ្ញុំ ។

សុគុណ : ហើយសាវ៉ាវ អត់មានដែរ និងវិហារអត់មានដែរ ៗបើមានកម្មវិធី?

សុផល : បើមានកម្មវិធី មកបុណ្យអីនៅតាត្រាវនេះ ។

សុគុណ : នៅតាត្រា និយាយចឹងមានដឹងថាវិហារនៅតាត្រាវហ្នឹងគេសាងសងនៅពេលណាដែរ?

សុផល : វិហារនៅគ្រានេះ កសាងមុនដំបូងឡើងវិហារតូចទិញផ្ទះគេមកពីកាពិលឆ្នាំ១៩៨៤ ដល់ឆ្នាំ១៩៩៣រើ អា....វាពុកទ្រុឌទ្រោមទៅបានអង្គការសហប្រជាជាតិ អ៊ុនតាត់យើងនេះ គេជួយរើមកនៅខាងលិច បានចាក់ជាគ្រឹះ ជាគ្រឹះរបងបង រៀបឥដ្ឋ ។

សុគុណ : ហើយក្រៅពីអ៊ុនតាក់មានខាងណាគេមកជួយទៀតទេ រឺក៏យើងមានបដិភាគចូលរួមខ្លះៗ ដែរប្រជាជន?

សុផល : គ្មានទេបងឥឡូវបើក្រទាំងអស់គ្នាទៅ ឥឡូវដុះស្មៅអស់ហើយ និយាយត្រង់តែម្តង ឥឡូវដុះស្មៅអស់ហើយ អ្នកដឹកនាំក៏ខ្សោយ ជីវភាពក៏ក្រ ខំរកស៊ីចិញ្ចឹមកូនរៀងៗខ្លួន ភ្លេចការអារខ្លះដែរ ថ្ងៃបុណ្យធំៗបានជួបជុំគ្នា ថ្ងៃស្រុក ថ្ងៃអី មិនបានមកទេ ព្រោះវាឆ្ងាយ ធ្វើដំណើរមកអស់មិនតិចលុយណា ។

សុគុណ : ចុះដូចជាកូនបងអី មានបានរៀនសូត្រពីគម្ពីខ្លះទេ?

សុផល : អត់ទាន់បានរៀនទេ.....អ៊ូកូនប្រុសខ្ញុំវាបានរៀន ខ្ញុំយកប្រពន្ធមេម៉ាយហ៊ា កូនប្រុសខ្ញុំរៀននៅសាលាលេខប្រាំហ៊ា រៀនខាងអ៊ីស្លាមតែម្តង ។

សុគុណ : ហើយចុះចំពោះសាលាចំនេះដឹងទូទៅវិញ?

សុផល : រៀនបាទ រៀនគ្រប់មុខជំនាញ រៀនអង់គ្លេសផង រៀនខ្មែរផង រៀនអ៊ីស្លាមផង ។

សុគុណ : ហើយកូនបងគេរៀនដល់ថ្នាក់ណាថ្នាក់ណីហើយ?

សុផល : វាទើបតែអាយុ ១០ឆ្នាំ ឥឡូវរៀនថ្នាក់ទី ៤ហើយ ។

សុគុណ : ហើយជាចុងក្រោយបងមានសល់អារូបថតចាស់ៗកាលពីមុនសល់សម័យប៉ុលពត រឺក៏មុនសម័យប៉ុលពតទេ?

សុផល : សម័យប៉ុលពតគ្មានទេបង ទៅរកម៉ាស៊ីនណាថត

សុគុណ : ហើយចុះមុនហ្នឹងមានទេបង?

សុផល : មុនមាន តែនៅផ្ទះអ៊ុំ នៅសល់យាយសល់ពូខ្ញុំ គាត់ជាទាហ៊ានខ្មែរក្រហម មិនដឹងទាហ៊ានខ្មែរក្រហមកាលហ្នឹង គាត់ថតកាន់កាំភ្លើងប៉ុន្តែនៅផ្ទះអ៊ុំខ្ញុំនៅព្រៃវែងនៅកំពង់ត្របែកហ៊ា នៅឃុំចក ។

សុគុណ : ហើយក្រៅពីរូបថត មាននៅឯកសារអីអត់?

សុផល : គ្មានទេបង នៅសល់តែពីអ្នក ស្នាដៃខ្មែរក្រហមនៅសល់តែពីរអ្នកបងប្អូន ។

សុគុណ : ហើយចុះឥឡូវម្តាយរបស់បងគាត់ស្លាប់ហើយ?

សុផល : គាត់អនិច្ចកម្មកាលឆ្នាំ១៩៨០ មកដល់ផ្ទះគាត់ឈឺស្លាប់តែម្តង គាត់រីងរៃគាត់រែក

គាត់ចាស់ មើលប្អូនឆ្នាំកើតឆ្នាំ១៩៧៧ ៧៩វា២ឆ្នាំ គាត់រែកមក គាត់ពរដាប់ សរសៃរឈឺស្លាប់ទៅ ។

សុគុណ : ហើយខ្ញុំចង់ដឹងតិចទៀតដូចថាក្រោយសំរាលកូនចឹងក្រោយរយះពេលប៉ុន្មាន គេប្រើអោយធ្វើការទៀតចឹង?

សុផល : អ្នកដែលមានផ្ទៃពោះឆ្លងទន្លេចឹងគេអាចបន្ធូរបន្ថយទោសដែរ ពេលយើងអ្នកមាន ផ្ទៃពោះចឹង ពេលឆ្លងទន្លេហើយគេទុកអោយយើងមានកំលាំងត្រឹមត្រូវ ។

សុគុណ : ប្រហែលជាប៉ុន្មានខែដែរបង?

សុផល : ប្រហែលជា៤-៥ខែបង ។

សុគុណ : ហើយកំឡុងពេលដែលគេអោយយើងសំរាកហ្នឹងគេមានទុកអោយយើងមានកំលាំង ហ្នឹងគេមានអោយយើងហូបចុកហូបអីធម្មតាទេបង?

សុផល : ហូបចុកដូចប្រជារាស្ត្រធម្មតា ដូចថាដូចប្រជាជនធម្មតា ។

សុគុណ : ដូចបាយ ១វែកអីចឹងដូចគេ ដូចឋងចឹង?

សុផល : ហ្នឹងហើយអាអ្នកកំលាំងធម្មតាចឹង គាត់ហូបស្មើកុមារ គាត់អត់មានពលកម្មគាត់ ហូបស្មើកុមារ ប៉ុន្តែរបបហូបនេះគឺរដូវវស្សាទេបង រដូវវស្សាគឺស្រូវវាខ្សោយ រដូវប្រាំងមិនខ្វះទេ ហូបសេរី រដូវវស្សាព្រោះស្រូវយើងថាបានប៉ុន្មានពាន់តោន ចឹងគេដាក់ឡានយកទៅប្រទេសចិន ទៅដូរអាវុធយកមកវៃគ្នា ។

សុគុណ : ឃើញគេដឹកឡានចឹងតែម្តង?

សុផល : បាទ ដឹកឡាន អាក្បាលតូចៗគេហៅអាវេរអីហ្នឹង ដឹកទៅប្រទេសចិន ដូរគ្រាប់យក មកវៃគ្នា ។

សុគុណ : ចុះបងមានដឹងគេដឹកឡានពីណាទៅណាទេ?

សុផល : ដឹកឡានចេញពីតាមភូមិ-ឃុំ គឺដឹកបញ្ជូនទៅអើគឺថាដឹកពីពិលមកកំពង់ត្រាចហ្នឹងមិនដឹង ថាបញ្ជូនតាមផ្លូវដឹកពីណាទៅណាទេ ។

សុគុណ : ហើយមេដឹកនាំគេមានប្រាប់ទៅអោយចិនអីចឹងទេ?

សុផល : ដឹងថាគេដឹកទៅលើៗ សម័យនោះមិនមែនចិនអោយគ្រាប់យើងទេ គឺយើងយកស្រូវ ទៅដូរគ្រាប់មកបាញ់ ។

សុគុណ : បាទសម័យណាក៏គេអត់អោយគ្រាប់មកយើងដែរ បើគេអោយ អោយកាំភ្លើង ។

សុផល : ខ្មែរយើងឆោតណាស់សម័យនោះ គេអោយកាំភ្លើងតែមិនអោយគ្រាប់ ចិនគេខ្វរ

ក្បារខ្ពស់ណាស់ គេអោយកាំភ្លើងយើងតែមិនអោយគ្រាប់ទេ គេសុខចិត្តលក់គ្រាប់ ១គ្រាប់ ១តៅហើយយើងយកមកបាញ់គ្នាឯងសាប់គ្នាឯងទៀត ។

សុគុណា : ចឹងដូចជាអស់សំនួរសួរបងហើយ អរគុណបងច្រើនដែរបានផ្តល់ជាពត៌មានដល់ពួកខ្ញុំ ។

សុផល : ខ្ញុំក៏សូមទោស ការខុសឆ្គងអីតិចតួច សូមអធ្យាស្រ័យព្រោះខ្ញុំជាប្រជារាស្ត្រធម្មតា មិនចេះដឹងអី មិនបានរៀនសូត្រជ្រៅជ្រះទេ ។

សុគុណា : ខ្ញុំក៏ជាប្រជាជនធម្មតាដូចបងដែរ គ្រាន់តែមកជួយមានឯកសារឯអី ដែលជាអ៊ីសំខាន់សំរាប់ប្រជាជនយើង ក៏ខំព្រយាមជួយចែកប្រជាជនអោយបានដឹង ។

សុផល : បាទៗស្វែងរកការពិត

សុគុណា : បាទៗនេះជារូបថតចាស់ៗអ្នកខ្លះដូចបាត់បង់បងប្អូនអីចឹងទៅគេសូមអោយមជ្ឈមណ្ឌលឯកសារកម្ពុជាជួយផ្សព្វផ្សាយដំនឹងអោយ ។

សុផល : បាទៗ

សុគុណា : ចឹងសូមអរគុណបងច្រើន ។

**«ចប់»**